ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៥៥៨
ចុះថ្ងៃទី ២០_០៧_០៦
សាលដីកា
លេខ : ៦០ "ខ"
ចុះថ្ងៃទី ១០_០៧_០៨

# ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

..........

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១០-០៧-២០០៨ ដោយមានសមាសភាព ដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- **លោក** [redacted] ជាប្រធានក្រុមប្រឹក្សា
- **លោក** [redacted] ជាចៅក្រមប្រឹក្សា
- **លោក** [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

**លោក** [redacted]

**ក្រឡាបញ្ជី**

**កញ្ញា** [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៥៥៨ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៦ ដែលមាន:

- **ជនជាប់ចោទឈ្មោ**[redacted]ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករលីសែង កើតនិងរស់នៅភូមិដើមដូង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ឪពុកឈ្មោ[redacted] រ) ម្តាយឈ្មោះ[redacted] រ) នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១១-០២-២០០៦ ឃុំខ្លួនថ្ងៃទី១៤-០២-២០០៦។

មានលោ[redacted]មេធាវីការពារ។

**ត្រូវជាប់ចោទពីបទ:** ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិដើមដូង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០០៦ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ១៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

- **ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ**[redacted]ភេទស្រី អាយុ២៨ឆ្នាំ មុខរបរលក់បាយ ទីលំនៅសព្វថ្ងៃនៅភូមិដើមដូង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង។

- **ជនរងគ្រោះឈ្មោ**[redacted]ភេទស្រី អាយុ៦ឆ្នាំ។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៧៩ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៦ របស់លោ[redacted]ព្រះរាជអាជ្ញារង ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៩ ខ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៦ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុចទី ១ នៃសេចក្តីសម្រេច។



Scanned by CamScanner

## ដំណើររឿងក្តីសង្ខេប:

កាលពីថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០០៦ វេលាម៉ោង៦ព្រឹក ខ្លួនលក់បាយ ប្តីទៅរត់រទេះសេះ ក៏ផ្ញើរកូន [redacted] ហៅ [redacted] អាយុ ៦ឆ្នាំ ជាមួយជីតា ស្រាប់[redacted]បបួលកូនខ្លួន ទៅលេងធ្វើខ្លែង មានក្មេងប្រុស [redacted] អាយុ៥ឆ្នាំ ទៅលេងជាមួយដែរ។ ពេលនោះ [redacted]ាប់កូនខ្លួនរំលោភ ដោយគំរាម [redacted]ថា បើប្រាប់ម៉ែឪវាសម្លាប់ចោល ឯកូនខ្លួនក៏ត្រូវវាគំរាមថា បើហ៊ាននិយាយប្រាប់គេ វាចាប់ដាក់ក្នុងអណ្តូងលូឱ្យងាប់។ លុះស្អែកថ្ងៃទី ១០-០២-២០០៦ ឈ្មោ[redacted]បបួលកូនខ្លួន ទៅកន្លែងដដែល ហើយ [redacted]មកប្រាប់ខ្លួន[redacted]កំពុងទាញដៃបបួល[redacted]ទៅលេងចុយគ្នាទៀតហើយ ខ្លួនទៅទាញដៃកូនមកវិញ[redacted]ក៏រត់បាត់។ ពេលខ្លួនដឹងភ្លាម ក៏ទៅប្តឹងមេភូមិ និងប៉ូលីស។ ហើយកូនខ្លួនបានប្រាប់ថា ពេល [redacted]រំលោភ វាយកដៃច្របាច់ក និងយកអាវញាត់មាត់ គំរាមមិនឱ្យស្រែក ហើយខ្លួនក៏ពិនិត្យប្រដាប់ភេទកូនឃើញមានសភាពញែក ជាំ ខ្លួនក៏នាំកូនទៅពិនិត្យនៅមន្ទីរពេទ្យធំខេត្តបាត់ដំបង ប៉ុន្តែគ្រូពេទ្យពុំបានផ្តល់វិញ្ញាបនប័ត្រឱ្យទេ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៨៩ ខ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៦ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ឱ្យឈ្មោះ[redacted]ភេទប្រុស អាយុ២០ឆ្នាំ រួចផុតពីបទចោទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិដើមដូង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០០៦ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ។ ក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៦៩១ ជសពស ចុះថ្ងៃទី២៥-០៥-២០០៦ របស់ព្រះរាជអាជ្ញាអមតុលាការខេត្ត និងដីកាបញ្ជូនរឿងឱ្យជម្រះលេខ ២៧៧៦ ពសព្រទ ចុះថ្ងៃទី២៥-០៥-២០០៦ របស់ចៅក្រមស៊ើបអង្កេត។

- តាមគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌ។

- យោងតាមមាត្រា ១៥២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

២- បង្គាប់ឱ្យឈ្មោ[redacted]ាអ្នកអាណាព្យាបាលលើឈ្មោ[redacted]ចញ្ចូលសំណងជម្ងឺចិត្តដល់ឈ្មោះ [redacted]ជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១លានរៀល ដើមបណ្តឹងរដ្ឋប្បវេណីទាមទារលើសពីនេះ បដិសេធចោល។

- តាមមាត្រា ១២១, ១២៣ និងមាត្រា១២៤ នៃក្រឹត្យច្បាប់លេខ ៣៨ ចុះថ្ងៃទី២៨-១០-១៩៨៨។

៣- សាលក្រមនេះជំនុំជម្រះជាសម្ងាត់ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោ[redacted] និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកអាណាព្យាបាលលើឈ្មោ[redacted]ទុករយៈពេលប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៧៩ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៦ របស់ពេ[redacted]ះរាជអាជ្ញារង ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៩ ខ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៦ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុចទី ១ នៃសេចក្តីសម្រេច។

55/3

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ ។
- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## ទាខេលសវនាការ

ចៅក្រមអានរបាយការណ៍រឿង

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោ[redacted]ឆ្លើយនៅតុលាការខេត្តបាត់ដំបង ។

ក្រឡាបញ្ជីអានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោ[redacted]ឆ្លើយនៅតុលាការខេត្តបាត់ដំបង ។

## សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

តាមចម្លើយរបស់ជនជាប់ចោទ ដែលបានឆ្លើយនៅដំណាក់កាលសួរយកចម្លើយនៅនគរបាល. អយ្យការ និង ចៅក្រមស៊ើបអង្កេត បានសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តមែន គឺរំលោភសេពសន្ថវៈទៅលើជនរងគ្រោះឈ្មោះ [redacted]ពិតប្រាកដមែន. ការដែលចៅក្រមជំនុំជម្រះសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទ ពុំមានលក្ខណៈត្រឹមត្រូវទេ គប្បីធ្វើប្រតិកោសល្យវិច័យដល់ថ្នាក់ជាតិ ដើម្បីបញ្ជាក់លើខួរក្បាលសសៃប្រសាទ តើមានជម្ងឺវិកលចរិក ឬយ៉ាងណា សូមឯកឧត្ដមប្រធានពិនិត្យ និង ពិចារណា ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវី

ខ្លួនសូមបញ្ជាក់ថា កូនក្ដីខ្លួនធ្លាប់ទទួលរងសំលេងមិននៅពីតូច និងមានលិខិតបញ្ជាក់ថា ឈ្មោះ[redacted] មានជម្ងឺសសៃប្រសាទ ហើយរយៈពេលជាប់ពន្ធនាគារក៏មានលិខិតបញ្ជាក់ថា ក្មេងនេះមានសតិស្មារតីវិបល្លាស ព្រោះរូបភាពដែលក្មេងមានអាយុ ២០ឆ្នាំ ទៅលេងជាមួយក្មេងនោះ ជារូបភាពខុសធម្មតា ហើយខ្លួនសូមឱ្យឈ្មោ[redacted] ចេញទៅព្យាបាលនៅខាងក្រៅ ។

- ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី
- ក្រោយពីបានពិភាក្សា រែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

១- បណ្ដឹងឧទ្ធរណ៍លេខ ៧៩ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៦ របស់លោកព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។

២- នៅចំពោះមុខនគរបាល អយ្យការ និងចៅក្រមស៊ើបអង្កេត ជនជាប់ចោទ បានឆ្លើយសារភាពថា កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៦ ខ្លួនពិតជាបានចាប់រំលោភសេពសន្ថវៈលើកុមារីរងគ្រោះឈ្មោះ[redacted] ពិតមែន លុះនៅសវនាការជនជាប់ចោទឆ្លើយបដិសេធថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។



Scanned by CamScanner

ប៉ុន្តែ តាមចម្លើយកុមារីរងគ្រោះថា កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៦ នោះ ជនជាប់ចោ[redacted] ពិតជាបានចាប់ខ្លួនរំលោភសេពសន្ថវៈមែន ពេលនោះ ខ្លួនឈឺ ក៏បម្រះ និងស្រែកយំ តែជនជាប់ចោទមិនឱ្យស្រែក ដោយគំរាមថា បើខ្លួនប្រាប់ម៉ែឪ វានឹងអារកខ្លួនសម្លាប់ ទម្លាក់ក្នុងលូ ពេលរំលោភខ្លួនឈឺ និងមានឈាម ។

៣- វិញ្ញាបនប័ត្រលេខ ១០១ មពប វិប ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៦ របស់មន្ទីរបង្អែកខេត្តបាត់ដំបងថា អ្នកជម្ងឺ (ជនជាប់ចោទ) មានជម្ងឺមនុស្សមិនគ្រប់លក្ខណៈ និងវិកលចរិក ។

ប៉ុន្តែ នៅឱកាសនៃការឆ្លើយនៅគ្រប់ដំណាក់កាលនៃនីតិវិធីបង្ហាញឱ្យឃើញថា ជនជាប់ចោទធ្វើប្រកបដោយវិចារណញ្ញាណ និងមានសតិល្អគ្រប់គ្រាន់ ឯនៅពេលប្រព្រឹត្តបទល្មើស ក៏បង្ហាញឱ្យឃើញថា មានសតិបញ្ញាល្អ យល់ដឹងនៅហេតុ និងផល នៃអំពើដែលខ្លួនប្រព្រឹត្តដែរ ។ ហេតុនេះហើយ បានជាជនជាប់ចោទគំរាមសម្លាប់កុមារីរងគ្រោះ បើកុមារីរងគ្រោះប្រាប់ម៉ែឪរបស់កុមារីអំពីប្រព្រឹត្តកម្មរបស់ខ្លួនលើកុមារី ។

៤- សកម្មភាពជនជាប់ចោទ គឺជាសកម្មភាពរំលោភសេពសន្ថវៈ តាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ប៉ុន្តែអយ្យការអមសាលាដំបូងខេត្តបាត់ដំបង សម្រេចចោទប្រកាន់ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ទៅវិញ ដូច្នេះ គួរកែប្រែឱ្យបានត្រឹមត្រូវឡើងវិញ ប្រព្រឹត្តនៅភូមិដើមដូង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០០៦ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៥- ចំណុចទី ១ នៃសាលក្រមព្រហ្មទណ្ឌលេខ ៨៩ ខ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៦ របស់តុលាការខេត្តបាត់ដំបង សម្រេចមានលក្ខណៈខុសឆ្គង ទាំងទម្រង់ និងទាំងគតិច្បាប់ គួរបដិសេធចោល ហើយសម្រេចឡើងវិញ ដូចយល់ឃើញខាងលើ ក្រៅពីនេះ គួរទុកនៅដដែល ។

**<u>ហេតុដូច្នេះ</u>**

**<u>វិនិច្ឆ័យសេចក្តី</u>**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៧៩ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៦ របស់លោកព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- បដិសេធចំណុចទី ១ នៃសាលក្រមព្រហ្មទណ្ឌលេខ ៨៩ ខ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៦ របស់តុលាការខេត្តបាត់ដំបង ចោលជាអសារបង់ ក្រៅពីនេះ ទុកនៅដដែល ។

៣- កែប្រែបទចោទប្រកាន់លើជនជាប់ចោទ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ទៅជាបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិដើមដូង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០០៦ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋវិញ ។

៤- ផ្តន្ទាទោសឈ្មោះ[redacted]ទប្រុស អាយុ ២០ ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករលីសែង លំនៅកំណើត និងលំនៅសព្វថ្ងៃនៅភូមិដើមដូង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ឪពុកឈ្មោ[redacted] (រ) ម្តាយឈ្មោ[redacted] រ) ដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៦



Scanned by CamScanner

ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិជើងមួង ឃុំមោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង តាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៥- បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទ ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted] | [redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ថ្ងៃទី ៣០ ខែ ០១ ឆ្នាំ២០០៥

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner